សូមជម្រាបសួរ នេះគឺជាពិពណ៌នាអំពីជីវប្រវត្តិ
ឬក៏សាច់រឿងរបស់ខ្ញុំទាក់ទងទៅនឹងការចូលរៀននៅក្នុងសាលាបឋមសិក្សា
ហើយកាលពីខ្ញុំនៅតូចគឺខ្ញុំបានចាប់ផ្ដើមចូលរៀន
ដំបូងគេគឺនៅក្នុងសាលាមួយហៅថាសាលាបឋមសិក្សាអង្គរបាន ហើយសាលាបឋមសិក្សា
នេះគឺស្ថិតនៅមិនឆ្ងាយពីផ្ទះរបស់ខ្ញុំប៉ុន្មានទេ
សាលាបឋមសិក្សាដែលខ្ញុំបានទៅស្ថិតនៅក្នុងភូមិរបស់ខ្ញុំ ហើយមានចំងាយប្រហែលជា
បើយើងដើរប្រហែលជា ១០ នាទីពីផ្ទះរបស់ខ្ញុំ ហើយបើធ្វើដំណើរដោយថ្មើរជើង គឺយើងដឹងថា [...]
ដើរទៅសាលានេះគឺចំណាយពេលប្រហែលជាតែ ១០ នាទីតែប៉ុណ្ណោះ
ពីផ្ទះរបស់ខ្ញុំទៅកាន់សាលាបឋមសិក្សាដែលខ្ញុំបានទៅ។ ហើយសាលាបឋមសិក្សានេះគឺ
ស្ថិតនៅក្បែរផ្ទះរបស់ខ្ញុំ ហើយខ្ញុំតែងតែធ្វើដំណើរដោយថ្មើរជើង
ដោយសារសាលាបឋមសិក្សានេះគឺស្ថិតនៅក្បែរផ្ទះ។ ហើយខ្ញុំបានចាប់ផ្ដើមរៀនដំបូងគេគឺ
ជាមួយនឹងម្ដាយរបស់ខ្ញុំ ម្ដាយរបស់ខ្ញុំគាត់គឺជាគ្រូបង្រៀន ហើយគាត់បង្រៀននៅថ្នាក់ទី ១
ហើយខ្ញុំបានចាប់ផ្ដើមទៅសាលាតាំងពីខ្ញុំ
នៅតូចដោយសារតែម្ដាយរបស់ខ្ញុំតែងតែយកខ្ញុំទៅសាលាជាមួយគាត់។ ហើយគាត់
ដោយសារអត់មានអ្នកជួយមើល គាត់តែងតែយកខ្ញុំទៅសាលា ដូច្នេះខ្ញុំបានទៅរៀនមុនអាយុ
គឺតាំងពីខ្ញុំនៅតូចម្លេះ។ គឺម្ដាយរបស់ខ្ញុំយកខ្ញុំទៅសាលា [...] រាល់ថ្ងៃជាមួយគាត់
ហើយខ្ញុំបានចាប់ផ្ដើមរៀន
ពេលដែលខ្ញុំគ្រប់អាយុចូលរៀនគឺខ្ញុំរៀនជាមួយម្ដាយរបស់ខ្ញុំនៅក្នុងថ្នាក់ដែលម្ដាយរបស់ខ្ញុំបង្រៀន។
ម្ដាយរបស់ខ្ញុំគាត់ជាគ្រូបង្រៀន ហើយគាត់បង្រៀននៅថ្នាក់ទី ១ ហើយ
ដឹងហើយថាកាលពីមុនគឺសាលាបឋមសិក្សានេះគឺ មានពីថ្នាក់ មត្តេយ្យ ថ្នាក់ទី ១
រហូតទៅដល់ថ្នាក់ទី ៥។ អញ្ចឹងសាលាបឋមសិក្សា គឺមានពីថ្នាក់មត្តេយ្យ ថ្នាក់ទី ១
រហូតទៅដល់ថ្នាក់ទី ៥ ដែលមាននៅក្នុងសាលាបឋមសិក្សានេះ។
ហើយកាលពីខ្ញុំនៅតូចគឺអត់ទាន់មានសាលាវិទ្យាល័យនៅឡើយទេ នៅក្នុងភូមិរបស់ខ្ញុំ
គឺមានតែសាលាបឋមសិក្សាតែប៉ុណ្ណោះ។
ហើយពេលដែលយើងចប់សាលាបឋមសិក្សានៅក្នុងភូមិគឺយើងត្រូវធ្វើដំណើរទៅកន្លែង
ឬក៏ភូមិផ្សេងទៀតដើម្បីបន្តថ្នាក់វិទ្យាល័យ ហើយខ្ញុំចាំបានថា
គឺខ្ញុំចូលចិត្តទៅសាលារៀនជាមួយម្ដាយរបស់ខ្ញុំ ហើយខ្ញុំចូលចិត្តពេលដែលម៉ោងសម្រាក
ពេលដែលម៉ោងសម្រាក គឺ យើងចេញទៅទិញនំ ទិញនំញ៉ាំ
ហើយពេលដែលខ្ញុំតែងតែរង់ចាំ[...]វៃជួង អញ្ចឹង នៅក្នុងសាលាបឋមសិក្សាគឺមានជួង
ដែលជាទូទៅពេលដែលឮជួងសំឡេងជួងវៃ គឺយើងអាចឈប់សម្រាកបាន
ហើយម៉ោងសម្រាកគឺយើងលេងល្បែងផ្សេងៗ ឬក៏លេងជាមួយមិត្តភក្តិហើយ ឬ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ក៏យើងទៅទិញអាហារសម្រន់ញ៉ាំ ហើយខ្ញុំចូលចិត្តម៉ោងសម្រាក
ដោយសារខ្ញុំអាចលេងជាមួយមិត្តភក្តិរបស់ខ្ញុំបាន ហើយខ្ញុំអាចញ៉ាំអាហារសម្រន់បានទៀត [...]
នេះគឺជាការចាប់ផ្តើមថ្នាក់បឋមសិក្សារបស់ខ្ញុំ
ដែលខ្ញុំបានរៀនជាមួយនឹងម្តាយរបស់ខ្ញុំដែលគាត់ជាគ្រូបង្រៀននៅថ្នាក់ទី ១
ដូច្នេះខ្ញុំបានចូលរៀនដំបូងគឺថ្នាក់ទី ១ តែម្តង សូមអរគុណ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.